# វប្បធម៌ឫស្សី និងឧបករណ៍តន្ត្រីខ្មែរ

ប្រជាជនខ្មែរភាគច្រើន ដែលរស់នៅក្នុងប្រទេសកម្ពុជា ជាពស្ត្រសាមញ្ញ កសិករ និងអ្នកនេសាទ ទាញយកការចិញ្ចឹមជីវិតពីទឹកដី ព្រៃឈើ បឹងបួរ ត្រពាំង ស្រះ ស្ទឹង និងទន្លេ។ កម្ពុជាជាប្រទេសមួយដែលសម្បូណ៌ទៅដោយធនធានធម្មជាតិ ស្រូវ ពោត សណ្តែក ផ្លែឈើ បន្លែ និងត្រី ដែលផ្តល់នូវការចិញ្ចឹមជីវិតសម្រាប់ប្រជាជនខ្មែរនៅតាមទីជនបទ និងទីក្រុង។

កម្ពុជា ជាជម្រកនៃប្រពៃណីសម្បូណ៌បែបនៃសិល្បៈទស្សនីយភាព រួមមានល្ខោន របាំ និងតន្ត្រី។ ក្នុងនោះ ខ្មែរយើងមានជាង២០ទម្រង់សិល្បៈទស្សនីយភាព ហើយទម្រង់នីមួយៗមានភ្លេងកំដរផង។

ឧបករណ៍តន្ត្រី មានច្រើនលើសលប់នៅប្រទេសកម្ពុជា ដែលធ្វើពីវត្ថុធាតុដើមជាច្រើនផ្សេងៗគ្នា មានដីឥដ្ឋ ឈើ ដែក ទង់ដែង ស្ពាន់ លង្ហិន នីឡុង ចំណែកឬគ្រឿងផ្សេងៗនៃសត្វ (ពោះវៀន ស្បែកសត្វតូច ស្បែកសត្វធំ រោម/សក់ ធ្មេញ និងលលាដ៍/សំបក/ស្នែក) រុក្ខជាតិ និងឫស្សី។

នៅក្នុងសង្គមកសិកម្មនៃប្រទេសកម្ពុជា គេតែងតែឮសូរសំឡេងផ្លុំស្លឹកឬសំឡេងខ្លុយលេងដោយក្មេងប្រុសជិះនៅលើខ្នងក្របីនៅកណ្តាលបឹងឬនៅក្នុងខ្ទមកណ្តាលវាលស្រែ ចាំចាបនិងសត្វពាហនៈកុំឱ្យវាស៊ីស្រូវនិងដំណាំដាំដុះរបស់គេ។

ឧបករណ៍តន្ត្រីធ្វើពីឫស្សីនៅកម្ពុជាមាន ដកម៉ែ ពីងពង់ ពក និងផ្លូវ។ ខ្មែរយើងប្រើឧបករណ៍ទាំងនេះនៅក្នុងវង់តន្ត្រីពិណពាទ្យនិងវង់តន្ត្រីប្រពៃណីជាច្រើនទៀតផងដែរ។

**ឧបករណ៍តន្ត្រីខ្មែរធ្វើពីឫស្សីនៃប្រទេសកម្ពុជា**

ខ្លុយ ប៉ីពក ប៉ីអ ឬប៉ីប្រុស ពួយ គែន អង្គួច ទ្រ គងរិង រនាតឯក រនាតធុង ក្រាប់គូ ក្រពះ កញ្ចែ និងកញ្ច្រាំ

**ឧបករណ៍តន្ត្រីជនជាតិដើមភាគតិចធ្វើពីឫស្សីនៃប្រទេសកម្ពុជា**

អត្ថបទដោយ៖

ជ្រួ ពី ហោតហូត ប្រាក ហ្កងណាក់ ហ្កងរិង ប្រូក ហ្កងទិង ជិងរៀង ហ្កងរេះ និងប៉ាស់ទូង

ក្រោពីធ្វើឧបករណ៍តន្ត្រីដូចបានរៀបរាប់ខាងលើនេះ គេយកឫស្សីទៅច្នៃធ្វើជាគ្រឿងសិល្បៈ សិប្បកម្ម និងឧបករណ៍ជាតិពន្ធុផ្សេងៗទៀតផងដែរ។

## References

Sam, Sam-Ang. (2001). *Musical instruments of Cambodia*. Osaka: National Museum of Ethnology.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖